# មុខតំណែង៖ អ្នកសម្របសម្រួលអភិវឌ្ឍន៍គ្រូគាំទ្របច្ចេកទេស

## បរិយាយការងារ

**អ្នកកាន់តំណែងនេះត្រូវរាយការណ៍ជូន:** ប្រធានគ្រប់គ្រងគម្រោងប្រចាំស្រុក

**ប្រភេទបុគ្គលិក:** ធ្វើការពេញម៉ោង (៤០ម៉ោងក្នុងមួយសប្តាហ៍)

**ទីកន្លែង:** ស្រុកជុំវិញ **ខេត្តសៀមរាប (១នាក់)** និង**ខេត្តបាត់ដំបង (២នាក់)**

**គោលបំណងការងារ:៖** មុខតំណែងនេះតម្រូវឲ្យមានការទទួលខុសត្រូវសម្រាប់គាំទ្រដល់ការអនុវត្តហើយ និងត្រួតពិនិត្យតាមដានដល់កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀន និងកម្មវិធីគាំទ្របច្ចេកទេស។

**ទំនួលខុសត្រូវចាំបាច់ក្នុងមុខតំណែងនេះ៖**

ការធ្វើការជាមួយអ្នកដែលពាក់ពន្ធ័ខាងក្រៅ ដូចជា គ្រូបង្រៀនកម្រិតបឋមសិក្សា នាយក និងគ្រូសារសិស្ស ដើម្បីអភិវឌ្ឍន៏នូវ ជំនាញរបស់ពួកគេក្នុងការអប់រំកុមារ។

ចូលរួមធ្វើការជាផ្នែកមួយនៃក្រុមដើម្បីសម្រេចផលសម្រេចដែលគ្រោងទុកតាមកម្មវិធី និងគោលបំណងរបស់អង្គការ និង ប្រមូលព័ត៌មាន និងទិន្នន័យពាក់ពន្ធ័ដើម្បីបង្ហាញពីភាពជោគជ័យ។

សកម្មភាពសំខាន់ៗនៅក្នុងតួនាទីនេះមានដូចជា៖

<table>
<tr><td colspan="2">ការធ្វើការជាមួយអ្នកដែលពាក់ពន្ធ័ ដូចជា គ្រូបង្រៀនកម្រិតបឋមសិក្សា នាយក និងគ្រូសារសិស្ស ដើម្បីអភិវឌ្ឍន៏នូវ ជំនាញរបស់ពួកគេក្នុងការអប់រំកុមារ</td></tr>
<tr><td></td><td>កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀន<ul><li>សម្របសម្រួល និងត្រួតពិនិត្យតាមដានកម្មវិធីគាំទ្របច្ចេកទេសនៅតាមសាលារៀន រួមទាំង អភិវឌ្ឍជំនាញ គ្រូបង្រៀន និងប្រមូលទិន្នន័យ។</li><li>ចូលរួមក្នុងការដឹកនាំវគ្គសិក្ខាសាលារបស់កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀនដោយធានាឲ្យមានភាពរលូន មានប្រសិទ្ធភាព និងគុណភាពខ្ពស់</li></ul></td></tr>
</table>

| | |
|---|---|
| | • ផ្តល់ការគាំទ្រដល់ប្រធានគ្រប់គ្រងកម្មវិធីនៅក្នុងការត្រួតពិនិត្យឡើងវិញនូវកម្មវិធីនិងធនធានសម្ភារៈ<br>**កម្មវិធីទំនាក់ទំនងសហគមន៍**<br>• ផ្តល់ការអប់រំទាក់ទងនិងកម្មវិធីគាំទ្រជាមួយក្រុមសហគមន៍ ឪពុកម្តាយ និងបុគ្គល។<br>• ទំនាក់ទំនងជាមួយនឹងឪពុកម្តាយ និងក្រុមសហគមន៍<br>• កសាងទំនាក់ទំនងល្អរវាងសាលារៀន ហើយនិង សហគមន៍<br>• ពង្រីកនូវការស្វែងយល់ពីបញ្ហារបស់សហគមន៍<br>• កសាងភាពជាម្ចាស់ និងនិរន្តភាពនៃហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនតាមរយៈការធ្វើផែនការ សាលារៀន ការចូលរួម ធ្វើវិភាគទាននិងការចូលរួមជាសកម្មភាព។<br>• សម្របសម្រួលលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ |
| ចូលរួមធ្វើការជាផ្នែកមួយនៃក្រុមដើម្បីសម្រេចបានតាមកម្មវិធី និងគោលបំណងរបស់អង្គការ និងប្រមូលពត៌មាន ហើយនិងទិន្នន័យដើម្បីបង្ហាញពីភាពជោគជ័យ។ | |
| | • ជួយជាមួយនិងការងារអភិវឌ្ឍនៅពេលមានក្រុមភ្ញៀវបរទេសចុះមកធ្វើទស្សនៈកិច្ច ជាពិសេសទាក់ទងនឹងការងារស្ម័គ្រចិត្តដែលធ្វើឡើងនៅ តាមសាលា<br>• ពង្រីក និងពង្រឹងទំនាក់ទំនងល្អមានប្រសិទ្ធិភាព ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំស្រុក និងអ្នកដែលពាក់ពន្ធ័ផ្សេងៗទៀត។<br>• ផ្តល់នូវវឌ្ឍនភាពនៃគម្រោងនេះទៅអ្នកពាក់ពន្ធ័ ដើម្បីធានាបាននូវ ទំនាក់ទំនងមានប្រសិទ្ធិភាព និងកសាងទំនាក់ទំនង។ |

## គុណសម្បត្តិ បទពិសោធន៍ និងសមត្ថភាព

| | |
|---|---|
| គុណសម្បត្តិ | |
| | • លក្ខណៈសម្បត្តិ ឬ បទពិសោធន៍ក្នុងការបង្រៀនដែល មានតម្លៃស្មើ<br>• មានចំណេះដឹងក្នុងវិស័យអប់រំ ជាគ្រូបង្រៀនឬសាស្ត្រាចារ្យគរុសល្យ |
| បទពិសោធន៍ | |
| | • មានប្រវត្តិជាគ្រូបង្រៀននៅសាលារដ្ឋ (ត្រូវការចាំបាច់) |

| | |
|---|---|
| | • មានបទពិសោធន៍ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលពីមុន (រឹតតែល្អ)<br>• មានបទពិសោធន៍ធ្វើការជាមួយសហគមន៍ដែលងាយរងគ្រោះពីមុន ((រឹតតែល្អ))<br>• មានបទពិសោធន៍មួយចំនួន និងការយល់ដឹងទៅលើការងារសំណង់ សុខភាព កីឡា និងកម្មវិធីអាហារូបករណ៍ (រឹតតែល្អ) |
| សមត្ថភាព | |
| | • មានជំនាញល្អក្នុងការទំនាក់ទំនង និងបកប្រែទាំងការសរសេរ និងនិយាយផ្ទាល់មាត់<br>• ចំណេះដឹងទូទៅផ្នែកបច្ចេកទេសបច្ចេកវិទ្យាខ្លះៗ<br>• មានជំនាញក្នុងការលើកទឹកចិត្ត និងចរចារបានល្អ<br>• មានសមត្ថភាពក្នុងការធ្វើការជាក្រុមបានយ៉ាងជិតស្និទ្ធ<br>• មានចំណេះដឹងផ្នែកភាសាអង់គ្លេស ទាំងការនិយាយ និងសរសេរ (រឹតតែល្អ) |
| ចរិកលក្ខណ:បុគ្គល | |
| | • ចាប់ផ្តើមដោយខ្លួនឯង ជាមួយសមត្ថភាពក្នុងការធ្វើការដោយឯករាជ្យ និងច្នៃប្រឌិត<br>• មានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងច្បាស់លាស់នៅគ្រប់កម្រិតទាំងអស់<br>• មានសមត្ថភាពក្នុងការបំពេញភារកិច្ចច្រើន ហើយផ្តោតទៅលើបញ្ហា និងដំណោះស្រាយ ហើយនៅតែរក្សាគោលដៅ និងមិនឆេវឆាវ។<br>• បង្ហាញកម្រិតយល់ដឹង ភាពរួសរាយរាក់ទាក់ ការឱនលំទោន ភាពប៉ិនប្រសប់ សម្មានចិត្ត ការព្រួយបារម្ភ និងសុភាពរាបសារ ក៏ដូចជាការទទួលស្គាល់ភាពខុសគ្នានៃវប្បធម៌ ពូជសាសន៍ ភេទ ពិការភាព និងភាពខុសគ្នារបស់បុគ្គលម្នាក់ៗ ដើម្បីកសាង ទំនាក់ទំនងឲ្យមានប្រសិទ្ធិភាព។ |

យើងលើកទឹកចិត្តបេក្ខជនទាំងពីរភេទ និងជាពិសេសជាស្ត្រី។